ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
លេខ.........០៧.................គជយ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន

## ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៤១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៦/៨១១ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៨នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៤១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន



អាសយដ្ឋានជាន់ទី៥ អគារថ្មីបឹងកេងកង ភ្នំពេញ កម្ពុជា ទូរសព្ទ៖ (៨៥៥-២៣)២១៣ ៣៤៥ ទូរសារ៖(៨៥៥-២៣) ២១៣ ៣៤៤ អ៊ីមែល៖ tauch.choeun@moeys.gov.kh

- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញអនុក្រឹត្យលេខ១៨៦ អនក្រ.តត ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមស្មារតីនៃកិច្ចប្រជុំលើកទី១របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន នាថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ដើម្បីជាយន្តការសម្របសម្រួលទំនាក់ទំនងរវាងក្រសួង ស្ថាប័ន ជាមួយគណៈកម្មការជំនាញចំណុះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (**ក.ជ.យ.**) អគ្គលេខាធិការដ្ឋាន នៃ **ក.ជ.យ.**និង **ក.ជ.យ.**។

**ប្រការ២ .-**

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ដឹកនាំដោយប្រធានមួយរូប ដែលជាសមាជិកនៃ **ក.ជ.យ.** និងមានអនុប្រធានចំនួនពីររូប ព្រមទាំងសមាជិកមួយចំនួនតាមការចាំបាច់ ដែលត្រូវបានជ្រើសរើសក្នុងចំណោមថ្នាក់ដឹកនាំឬមន្ត្រីរាជការស៊ីវិលដែលមានបទពិសោធលើការងារយុវជនឬដែលកំពុងធ្វើការងារយុវជន។

ស្ត្រីត្រូវបានផ្តល់អាទិភាពឱ្យចូលរួមក្នុងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន។

សមាសភាពរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ជ.យ.** តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នសាមី។

**ប្រការ៣ .-**

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ដែលមានទីតាំងនៅក្នុងក្រសួង ស្ថាប័ននីមួយៗ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន តាមសំណើរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន។

**ប្រការ៤ .-**

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន មានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេស ដើម្បីជួយការងារពាក់ព័ន្ធនឹងការអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន។

សមាសភាព តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័ន តាមសំណើរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន។

**ប្រការ៥ .-**

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័នមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងការងារយុវជននៅក្នុងក្រសួង ស្ថាប័ន
- រៀបចំផែនការសកម្មភាព កម្មវិធី សេវាកម្ម និងសកម្មភាពផ្សេងៗដើម្បីឧត្តមប្រយោជន៍របស់យុវជនក្រសួង ស្ថាប័ន
- ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្តសន្ធិសញ្ញានានាពាក់ព័ន្ធយុវជន ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានៅក្រសួង ស្ថាប័ន និងលើកសំណើជូន **គ.ជ.យ.** ដើម្បីដោះស្រាយ និងធានាឧត្តមប្រយោជន៍របស់យុវជនក្រសួង ស្ថាប័ន
- ធ្វើការផ្សព្វផ្សាយច្បាប់ សន្ធិសញ្ញានានាពាក់ព័ន្ធយុវជន គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និង **គ.ជ.យ.** ពាក់ព័ន្ធនឹងបញ្ហារបស់យុវជន បំផុសចលនាគាំទ្រ និងចូលរួមអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឱ្យមានប្រសិទ្ធភាព
- ធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជនដែលមានគម្រោងការងារពាក់ព័ន្ធយុវជននៅក្នុងក្រសួង ស្ថាប័ន ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធ និងទស្សនៈរីកចម្រើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការអភិវឌ្ឍយុវជន
- រៀបចំមូលដ្ឋានទិន្នន័យស្តីពីស្ថានភាពយុវជននៅក្នុងក្រសួង ស្ថាប័ន
- សហការរៀបចំទិវាអន្តរជាតិសម្រាប់យុវជន ១២ សីហា
- សហការអនុវត្តគោលការណ៍និងផែនការសកម្មភាពរបស់ **គ.ជ.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារតាមកាលកំណត់ ជូន **គ.ជ.យ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែល **គ.ជ.យ.** ប្រគល់ជូន។

**ប្រការ៦ .-**

អនុប្រធាននិងសមាជិកនៃក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាពចំណុះនានា អង្គការសង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍនានា និងអ្នកជំនាញដើម្បីចូលរួម ប្រជុំផ្តល់យោបល់បាន។

**ប្រការ៧ .-**

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័នមានសិទ្ធិប្រើនិមិត្តសញ្ញា **គ.ជ.យ.** និងត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។ គំរូនិមិត្តសញ្ញានិងត្រា ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។ គំរូត្រារបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ត្រូវតម្កល់នៅអគ្គលេខាធិការដ្ឋាន នៃ **គ.ជ.យ.**។

**ប្រការ៨ .-**

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័នអាចប្រើប្រាស់កញ្ចប់ថវិការបស់ក្រសួង ស្ថាប័នសាមីដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ប្រធានក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ......០៣....ក.ជ.យ
## ចុះថ្ងៃទី២៧ខែ.កញ្ញា..ឆ្នាំ.២០១៦...
## ស្តីពី
## ការបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួងស្ថាប័ន ត្រូវប្រើទម្រង់និមិត្តសញ្ញានិងត្រាដូចខាងក្រោម៖

**ក- និមិត្តសញ្ញា**

- ប្រើប្រាស់និមិត្តសញ្ញារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- សរសេរអក្សរ" **ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន**" នៅខាងក្រោមនិមិត្តសញ្ញារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន។

*គំរូនិមិត្តសញ្ញា*

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន**
**ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ឬ ស្ថាប័ន.......................**

**ខ- ត្រា**

ត្រារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនមានទម្រង់និងខ្លឹមសារដូចខាងក្រោម៖

*១-ទម្រង់*

- មានរាងរង្វង់មូល
- មានខ្សែព័ទ្ធខាងក្រៅចំនួនពីរជាន់និងខាងក្នុងចំនួនមួយជាន់
- នៅចំកណ្តាលមានរូបប្រាសាទកំពូលបី។

*២-ខ្លឹមសារ*

- ខាងលើដាក់ថា "**ព្រះរាជាណាចក្រកម្ពុជា**"
- ខាងក្រោមដាក់ថា "**ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន**"។

*គំរូត្រា*